**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៥/២០០៥ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥

**ជូនចំពោះ**
**លោក ខែម សាសនា**

**កម្មវត្ថុ** : បណ្ដឹងរបស់លោកលេខ ០០២៤ គសចជន ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៥

ដូចកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោកថា ក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥ ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចថា បណ្ដឹងរបស់លោកលេខ ០០២៤ គសចជន ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៥ មិនអាចយកមកពិនិត្យបានទេ ពីព្រោះបណ្ដឹងនេះមិនស្របនឹងវាក្យខ័ណ្ឌទី១នៃមាត្រា ២៥ ជំពូកទី៥ នៃច្បាប់ស្ដីពីគណបក្សនយោបាយ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ដែលចែងថា " *គណបក្សនយោបាយ ដែលក្រសួងមហាផ្ទៃបានចេញលិខិតមិនយល់ព្រមឱ្យចុះបញ្ជីគណបក្សនយោបាយ ដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ គណបក្សនយោបាយនោះមានសិទ្ធិប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ។* " និងមាត្រា ២៦ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ។ល

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ
ប្រធាន

ប៊ិន ឈិន

អគារ "៥៦" វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ : (០២៣) ៧២៦ ០៣០ ឬ (០២៣) ៧២៦ ០៣៤ ហ្វាក់ (៨៥៥) ២៣ ៧២០ ៩១៣ អ៊ីមែល : sgcc@camnet.com.kh